# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

No. 26 PR-17/EoJ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧

## មហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ីឆ្នាំ២០១៧

## ការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជា

កម្មវិធីប្រលងជ្រើសរើសវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជានៃមហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ីឆ្នាំ២០១៧បានប្រព្រឹត្តិទៅយ៉ាងជោគជ័យនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងដោយស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន។ ប្រធានបទដែលត្រូវបកស្រាយក្នុងឆ្នាំនេះគឺ“**គ្រូបង្រៀន**”។ មានភាពយន្តចំនួន២៨រឿងដែលផលិតដោយសិស្ស១២វិទ្យាល័យទូទាំងប្រទេសកម្ពុជាបានដាក់ពាក្យចូលរួមប្រកួត ហើយក្នុងចំណោមនោះមានភាពយន្តចំនួន១៥ ត្រូវបានសម្រិតសម្រាំងដើម្បីចាក់បញ្ចាំងក្នុងការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រនេះ។

មហោស្រពភាពយន្តនេះ បានចាប់ផ្តើមនៅប្រទេសជប៉ុនតាំងពីឆ្នាំ២០០៧មកម្លេះ ហើយចាប់តាំងពីពេលនោះមកគឺមហោស្រពនេះបានចាប់ផ្តើមប្រារព្ធឡើងជារៀងរាល់ឆ្នាំ។ ចំណែកសិស្សានុសិស្សកម្ពុជាវិញត្រូវបានអញ្ជើញអោយចូលរួមក្នុងមហោស្រពនេះតាំងពីឆ្នាំ២០០៩។ ឆ្នាំនេះ សិស្ស៣ក្រុមដែលមានចំនួនសរុប៩រូប(ឈ្មោះមានភ្ជាប់នៅតារាងខាងក្រោម)នឹងត្រូវបានអញ្ជើញទៅកាន់ប្រទេសជប៉ុន ក្រោមកម្មវិធី JENESYS2017 ជាមួយបណ្តាសិស្សមកពីប្រទេសអាស៊ានទាំង១០ ព្រមជាមួយទីម័រខាងកើត ចិន ចិនតៃវ៉ាន់ ម៉ុងហ្គោលី កូរ៉េខាងត្បូង និងប្រទេសជប៉ុន។ សិស្សជ័យលាភី៣ក្រុមក្នុងវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រនេះនឹងចូលរួមវគ្គផ្តាច់ព្រ័ត្រនៃមហោស្រពនេះនៅទីក្រុងគីតាមិ កោះហុកកៃដូ ប្រទេសជប៉ុន នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៧។

យើងសង្ឃឹមថាសិស្សកម្ពុជានឹងទទួលបានជោគជ័យនៅក្នុងកម្មវិធីមហោស្រពខាងមុខនេះ ព្រមទាំងសប្បាយរីករាយសម្រាប់ការកសាងមិត្តភាពជាមួយអ្នកចូលរួមដទៃទៀត។

ភាពយន្តខ្លីចំនួន៣រឿងដែលបានជ្រើសរើសចូលរួមក្នុងវគ្គផ្តាច់ព្រ័ត្រមហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ីឆ្នាំ២០១៧នេះមានរាយដូចខាងក្រោម៖

| Prize | Name of Students | Film Titles | High Schools |
|---|---|---|---|
| 1st | Sok Pichmonineath | Same mother, different wombs | CAMBODIA ADVENTIST SCHOOL |
| | Rith Sereyvattanak | | |
| | Khat Sodavan | | |
| 2nd | Chhorn Chandarasavvin | My second parents | TUOL TOMPOUNG |
| | Chuon Panhabotr | | |
| | Seak Sreyleang | | |
| 3rd | Sokhoeun Rathvireaksith | Liar | PREAH SISOWATH |
| | Meung Chansomanita | | |
| | Mam Sanora | | |



រូបថតក្រុមជ័យលាភីជាមួយគណៈកម្មការ